ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៩៧១ សហវ.ប្រក.

# ប្រកាស

## ស្តីពី

## ការបង្កើត លេខាធិការដ្ឋាននៃគណៈកម្មាធិការឥណទានសំរាប់អភិវឌ្ឍន៍ជនបទ

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៨៨ ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងឥស្សរជនជាអនុរដ្ឋលេខាធិការនៃក្រសួងនិងរដ្ឋលេខាធិការដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៧៨/អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៦៧ អនក្រ បក ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីកែសំរួល សមាសភាព

និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការឥណទានសំរាប់អភិវឌ្ឍន៍ជនបទ

- បានឃើញ ប្រកាសលេខ ៥៨៤/សហវ/ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសំរួលការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**ប្រការ១:** បង្កើតលេខាធិការដ្ឋាននៃគណៈកម្មាធិការឥណទានសំរាប់អភិវឌ្ឍន៍ជនបទ(**គឥអ**) ដែលស្ថិតនៅក្រោមនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយលេខាធិការដ្ឋាននេះមានការិយាល័យគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ និង ហិរញ្ញប្បទានសំរាប់សហគ្រាសធុនតូច និង មធ្យមជាសេនាធិការ ។

**ប្រការ២:** លេខាធិការដ្ឋាននៃ **គឥអ** មានតួនាទី និង ភារកិច្ចដូចខាងក្រោមះ

- ជាសេនាធិការអោយ **គឥអ**
- សំរបសំរួលការងាររដ្ឋបាលទូទៅរបស់លេខាធិការដ្ឋានជាមួយស្ថាប័នពាក់ពន្ធ័ផ្សេងៗក្នុងក្របខណ្ឌ័ **គឥអ**
- រៀបចំកិច្ចប្រជុំ សំណុំលិខិត ឯកសាររដ្ឋបាលផ្សេងៗតាមរយៈការណែនាំរបស់ **គឥអ**
- រៀបចំធ្វើរបាយការណ៍ជូនសមាជិកនៃ **គឥអ** និង ស្ថាប័នពាក់ពន្ធ័ផ្សេងៗទៀត អំពីសកម្មភាពមីក្រូហិរញ្ញវត្ថុទាំងអស់
- ចូលរួមរៀបចំក្របខណ្ឌ័យុទ្ធសាស្ត្រ និង គោលនយោបាយជាតិក្នុងវិស័យមីក្រូហិរញ្ញវត្ថុ សំរាប់ការអភិវឌ្ឍន៍ជនបទ ដើម្បីដាក់ជូន **គឥអ** ពិនិត្យ និង អនុម័ត
- សំរបសំរួល និង តាមដានការអនុវត្តយុទ្ធសាស្ត្រ និង គោលនយោបាយជាតិក្នុងវិស័យមីក្រូហិរញ្ញវត្ថុ តាមរយៈចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុសំរាប់ឆ្នាំ ២០០១-២០១០ របស់រាជរដ្ឋាភិបាល
- រៀបចំកម្មវិធី និង ផែនការសកម្មភាព ដើម្បីអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ រួមមានការគៀងគរជំនួយពីបរទេស ទ្វេភាគី និង ពហុភាគី សំរាប់តំរូវការឥណទានជនបទ ព្រមទាំងជំរុញឱ្យស្ថាប័នហិរញ្ញវត្ថុក្នុងស្រុកចូលរួមចំណែកគាំទ្រដល់ការអភិវឌ្ឍន៍វិស័យឥណទានជនបទនៅកម្ពុជា ដើម្បីដាក់ជូន **គឥអ** ពិនិត្យ និង សំរេច
- តាមដានការប្រើប្រាស់ និង ការអនុវត្តន៍គំរោងឥណទានសំរាប់អភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុដែលទទួលបានហិរញ្ញប្បទានពីរាជរដ្ឋាភិបាល ពីស្ថាប័នហិរញ្ញវត្ថុជាតិ និង អន្តរជាតិ ពីប្រទេសជាមិត្ត និង ពីប្រភពឥណទានផ្សេងទៀត ដើម្បីធានាឱ្យការប្រើប្រាស់ឥណទានទាំងនេះ ស្របតាម

យុទ្ធសាស្ត្រ និង គោលនយោបាយជាតិដែលបានកំណត់

- ចូលរួមតាមដានប្រតិបត្តិការនៃការផ្តល់ឥណទានធនធានរបស់ស្ថាប័ន ឬ ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ដែលមានអាជ្ញាបណ្ណ ឬ ចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា ដើម្បីធានាឱ្យបាននូវប្រសិទ្ធិភាព និង និរន្តភាពនៃហិរញ្ញប្បទានលើវិស័យនេះ
- ចូលរួមរៀបចំក្នុងការកសាងសមត្ថភាពស្ថាប័នគ្រប់គ្រង និង សមត្ថភាពប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ តាមរយៈការរៀបចំសិក្ខាសាលាជាតិ-អន្តរជាតិ និងការស្វែងរកជំនួយផ្សេងៗ ដើម្បីពង្រឹងសមត្ថភាពលើវិស័យនេះ
- ចូលរួមផ្តល់យោបល់ និង នាំមកនូវគំនិតថ្មីៗដើម្បីចូលចំណែកក្នុងការអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុ ជូន **គជឧាន**
- បំពេញភារកិច្ចផ្សេងទៀតដែលប្រធាន **គជឧាន** ណែនាំ ។

**ប្រការ៣:** ប្រកាស ឬ លិខិតបទដ្ឋានទាំងឡាយ ដែលផ្ទុយពីសេចក្តីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក និង គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៥

**គាត ឈន់**

**ចំលងជូន:**

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ធនាគារជាតិនៃកម្ពុជា
-ធនាគារអភិវឌ្ឍន៍ជនបទ
-គណៈកម្មាធិការ (គជឧាន)
" ដើម្បីជូនជ្រាបជាព័ត៌មាន និង សហការ "
-ដូចប្រការ ៤ " ដើម្បីអនុវត្ត "
-ឯកសារ-កាលប្បវត្តិ